# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ ពិពណ៌នាពីសូចនាករសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅអាស៊ីខាងកើត។

## កំណើនសេដ្ឋកិច្ចពិភពលោក

បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត បន្តនាំមុខក្នុងការងើបឡើងវិញ ស្របពេលដែលប្រទេសឧស្សាហកម្មធំៗ កំពុងប្រឹងងើបឡើងវិញនៅឡើយពីវិបត្តិសេដ្ឋកិច្ចនេះ ដែលធ្ងន់ធ្ងរបំផុតចាប់តាំងពីមហាវិបត្តិក្នុងទសវត្សរ៍១៩៣០ នោះមក។ ចំណាយប្រើប្រាស់ផ្នែកឯកជនកំពុងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ខណៈដែលអន្តរាគមន៍ផ្នែកសារពើពន្ធ និងរូបិយវត្ថុ បាននិងកំពុងមានភាពប្រក្រតីឡើងវិញ។ ទោះយ៉ាងនេះក្ដី កំណើនសេដ្ឋកិច្ចពិភពលោកជារួមមានល្បឿនយឺតជាងកាលពីមួយឆ្នាំមុន។

ក្នុងត្រីមាសទី១ ឆ្នាំ២០១១ ផសស ពិតរបស់ឥណ្ឌូនេស៊ី កើន ៦,៥% ធៀបនឹងឆ្នាំមុន ស្របពេលដែលវៀតណាម កើន ៥,៤% ប៉ុន្តែ ផសស ពិតរបស់ម៉ាឡេស៊ី សិង្ហបុរី និងថៃ បានធ្លាក់ចុះ។ ផសស របស់ម៉ាឡេស៊ី មានកំណើន ៤,៦% រីឯសិង្ហបុរី មាន ៨,៣%។ កំណើន ផសស នៅថៃ បន្តធ្លាក់ចុះដល់ ៣% ដោយសារជាសំខាន់មកពីវិបត្តិនយោបាយក្នុងស្រុកដែលកំពុងបន្តកើតមាន និងជម្លោះព្រំដែនជាមួយកម្ពុជា។ ទោះជាមានកំណើនយឺតជាងកាលពីមួយឆ្នាំមុនក្ដី ចិន នៅតែទទួលបានលទ្ធផលល្អ ដោយមានកំណើន ផសស ៩,៧%។ កំណើន ផសស នៅហុងកុង មានកម្រិត ៧,២% ចំណែកឯកូរ៉េខាងត្បូង មាន ៤,២%។

សេដ្ឋកិច្ចរបស់ប្រទេសឧស្សាហកម្មធំៗ ចាប់ផ្ដើមងើបឡើងវិញក៏ពិតមែន ប៉ុន្តែពួកគេកំពុងប្រឹងប្រែងនៅឡើយដើម្បីឡើងឲ្យដល់កម្រិតដូចនៅមុនពេលមានវិបត្តិ។ នៅត្រីមាសទី១ ឆ្នាំ២០១១ អត្រាកំណើន ផសស ក្នុងប្រទេសប្រើប្រាក់អឺរ៉ូទាំង ១២ កើនដល់ ២,៥% ធៀបនឹងឆ្នាំមុន ស្របពេលដែល ផសស នៅសហរដ្ឋអាមេរិក មានកំណើន ២,៣%។ ក្នុងត្រីមាសនេះដែរ ការធ្លាក់ចុះសេដ្ឋកិច្ចកំពុងគំរាមកំហែងប្រទេសជប៉ុន ដោយសារការរញ្ជួយដីដ៏ធំដែលបានបំផ្លិចបំផ្លាញប្រទេសនេះកាលពីខែមីនា ធ្វើឲ្យស្លាប់មនុស្សរាប់ពាន់នាក់ និងខូចខាតរោងចក្រនុយក្លេអ៊ែរមួយកន្លែងទៀត។ កង្វល់អំពីការលេចធ្លាយជាតិវិទ្យុសកម្ម បានប៉ះពាល់ធ្ងន់ធ្ងរដល់ចំណាយប្រើប្រាស់ក្នុងស្រុក និងជញ្ជីងពាណិជ្ជកម្មរបស់ជប៉ុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

ទោះមានការងើបឡើងវិញក្ដី ក៏សេដ្ឋកិច្ចពិភពលោកនៅតែប្រឈមនឹងបញ្ហាបន្ទាន់មួយ គឺអតិផរណាបន្តនៅខ្ពស់ដដែល។ នៅត្រីមាសទី១ ឆ្នាំនេះ នៅបណ្ដាប្រទេសមានសេដ្ឋកិច្ចធំៗក្នុងពិភពលោក អតិផរណាបានកើនឡើង បើធៀបនឹងកាលពីមួយឆ្នាំមុន។ ពួកអ្នករៀបចំគោលនយោបាយក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ក៏ត្រូវប្រយ័ត្នប្រយែងចាត់វិធានការដើម្បីទប់ស្កាត់អតិផរណាផងដែរ។

នៅត្រីមាសទី១ ឆ្នាំនេះ អតិផរណា នៅឥណ្ឌូនេស៊ី កើន ៦,៨% ធៀបនឹងឆ្នាំមុន ហើយនៅសិង្ហបុរី កើន ៥,២%។ ដោយសារគោលនយោបាយពង្រីកហិរញ្ញវត្ថុ ប្រទេសវៀតណាមកំពុងបន្តប្រយុទ្ធនឹងអតិផរណាកម្រិតខ្ពស់ដល់ ១២,៨%។ ចំណែកឯប្រទេសកម្ពុជា និងថៃ គឺអាចរក្សាបាននូវអត្រាអតិផរណាសមរម្យ ត្រឹម ៣,៦% និង ៣,០%។ អត្រាអតិផរណានៅបណ្ដាប្រទេសអាស៊ីខាងកើត បន្តកើនឡើងនៅត្រីមាសទី១ ឆ្នាំ២០១១ បើធៀបនឹងកាលពីមួយឆ្នាំមុន។ អត្រាអតិផរណានៅចិន កើនដល់ ៥,១% ហុងកុង ដល់ ៤,០% និង កូរ៉េខាងត្បូង ៤,៤%។ ក្នុងពេលជាមួយគ្នា ប្រទេសប្រើប្រាក់អឺរ៉ូទាំង១២ មានកំណើនអតិផរណាដល់ ២,៥% ស្របពេលដែលអតិផរណានៅសហរដ្ឋអាមេរិក ធ្លាក់ចុះបន្តិចមកត្រឹម ២,១% និងនៅជប៉ុនមានអត្រាស្មើសូន្យ។

នៅត្រីមាសទី១ ឆ្នាំ២០១១ អត្រាប្ដូរប្រាក់របស់ប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើន ក្រៅពីវៀតណាម បានកើនឡើងធៀបនឹងដុល្លារអាមេរិក។ ប្រាក់រៀល ឡើងថ្លៃ ៣,៣% ដល់ ៤០៤១,៩រៀល/ដុល្លារUS ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ឡើង ៤% ដល់ ៨៩០២,០២រូពីយ៉ា/ដុល្លារUS ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៩,៥% ដល់ ៣,០៥រីងហ្គីត/ដុល្លារUS ប្រាក់ដុល្លារសិង្ហបុរី ឡើងថ្លៃ ៨,៦% ដល់ ១,២៨ដុល្លារសិង្ហបុរី/ដុល្លារUS និងប្រាក់បាតថៃ ឡើងថ្លៃ ៧,១% ដល់ ៣០,៥៦បាត/ដុល្លារUS។ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៧,៦% រហូតដល់ ២០.២៧៣ដុង/ដុល្លារUS។ ក្នុងរយៈដូចគ្នានេះ អត្រាប្ដូរប្រាក់អឺរ៉ូ នៅថេរធៀបនឹងដុល្លារអាមេរិក ខណៈពេលដែលប្រាក់យេនជប៉ុន ឡើងថ្លៃ ៩,២% ដល់ ៨២,៣យេន/ដុល្លារUS។

## ថ្លៃទំនិញក្នុងទីផ្សារពិភពលោក

ថ្លៃទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោក បន្តកើនឡើងនៅត្រីមាសទី១ ឆ្នាំនេះ បើធៀបនឹងកាលពីមួយឆ្នាំមុន។ ភាពតានតឹងនៅមជ្ឈិមបូព៌ា និងវិបត្តិនុយក្លេអ៊ែរនៅជប៉ុន បានរួមចំណែកដល់ការរំពឹងទុកអំពីការឡើងថ្លៃប្រេងកាន់តែខ្ពស់។ ពោត (USNo.2) ឡើងថ្លៃ ៧២% ដល់ ២៨០,៣២ដុល្លារ/តោន ប្រេងដូង (north-west) ឡើងថ្លៃ ៥៥% ដល់ ១២៥១ដុល្លារ/តោន និងជ័រកៅស៊ូ (SMR 5) ឡើងថ្លៃ ៧០% ដល់ ៥២៧៨,០៣ដុល្លារ/តោន។ ក្នុងរយៈពេលដូចគ្នា ប្រេងឆៅ (OPEC spot) ឡើងថ្លៃ ៣៣% ដល់ ១០០,៧ដុល្លារ/ធុង សាំង (US Gulf Coast) ឡើងថ្លៃ ២៦% ដល់ ០,៦៨ដុល្លារ/លីត្រ និងប្រេងម៉ាស៊ូត (low sulphur No.2) ឡើងថ្លៃ ៣៥% ដល់ ០,៧៣ដុល្លារ/លីត្រ។ អង្ករ (Thai 100% B) ធ្លាក់ថ្លៃ ៦,៦% មកត្រឹម ៥២៨,២៥ដុល្លារក្នុងមួយតោន។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅ វិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 | 5.8 | 6.9 | 6.5 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9 | 8.9 | 5.3 | 4.8 | 4.6 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4 | 18.7 | 10.5 | 12.0 | 8.3 |
| ថៃ | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.2 | 6.7 | 3.8 | 3.0 |
| វៀតណាម | 8.1 | 8.5 | 6.2 | - | - | - | - | 5.8 | 6.4 | 7.2 | 7.3 | 5.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1 | 10.7 | 11.9 | 10.3 | 9.7 | 9.8 | 9.7 |
| ហុងកុង | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0 | 6.5 | 6.8 | 6.2 | 7.2 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 | 4.5 | 4.8 | 4.2 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4 | 14.6 | 12.9 | 9.8 | 6.9 | 6.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | 0.6 | 1.7 | 1.9 | 2.0 | 2.5 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 5.5 | 3.5 | 5.0 | 2.2 | -1.0 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 2.6 | 2.8 | 2.9 | 2.3 | 2.8 | 2.3 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 | 6.2 | 6.3 | 6.8 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.6 | 1.9 | 2.1 | 2.8 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.1 | 3.4 | 4.0 | 5.2 |
| ថៃ | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 3.3 | 3.3 | 2.0 | 3.0 |
| វៀតណាម | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | 9.0 | 8.4 | 10.9 | 12.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1 | 2.7 | 3.3 | 4.7 | 5.1 |
| ហុងកុង | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.6 | 2.3 | 2.9 | 4.0 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 | 2.9 | 3.6 | 4.4 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3 | 1.3 | 1.1 | 0.4 | 1.1 | 1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 | 1.7 | 2.0 | 2.5 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 | -0.9 | 0.1 | 0.0 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 | 1.2 | 1.3 | 2.1 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 | 4236.69 | 4122.58 | 4041.90 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 10,225.00 | 9887.00 | 9472.44 | 9266.93 | 9,132.00 | 8995.11 | 8965.70 | 8902.02 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.70 | 3.30 | 3.30 | 3.50 | 3.50 | 3.40 | 3.37 | 3.24 | 3.15 | 3.11 | 3.05 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 4.58 | 1.45 | 1.44 | 1.39 | 1.40 | 1.36 | 1.36 | 1.30 | 1.28 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 33.98 | 33.96 | 33.30 | 32.90 | 32.33 | 31.63 | 29.99 | 30.56 |
| វៀតណាម (ដុង) | 15,994.00 | 16,030.00 | 16,382.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 | 18,993.00 | 19,485.00 | 19499.48 | 20273.83 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ាន់) | 7.97 | 8.03 | 6.94 | 6.83 | 6.83 | 6.83 | 6.83 | 6.77 | 6.77 | 6.66 | 6.58 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.76 | 7.78 | 7.77 | 7.76 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 | 1182.41 | 1132.85 | 1120.19 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 33.10 | 32.77 | 32.29 | 31.93 | 31.90 | 31.90 | 30.36 | 29.30 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.71 | 0.70 | 0.68 | 0.72 | 0.79 | 0.77 | 0.74 | 0.73 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 95.95 | 93.58 | 89.78 | 90.73 | 92.20 | 85.74 | 82.53 | 82.33 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 171.16 | 146.85 | 168.13 | 162.88 | 157.41 | 176.13 | 238.81 | 280.32 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 719.35 | 659.16 | 732.33 | 807.67 | 813.00 | 874.67 | 1108.00 | 1251.00 |
| កៅស៊ូ SMR 5 | 1996.30 | 2202.30 | 2586.30 | 1638.77 | 1924.80 | 2536.03 | 3105.90 | 3083.73 | 3175.97 | 4257.27 | 5278.03 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 499.45 | 307.31 | 569.00 | 565.67 | 461.33 | 468.33 | 531.00 | 528.25 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 420.10 | 411.18 | 390.43 | 372.68 | 370.95 | 406.88 | 480.24 | 537.24 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 57.46 | 68.32 | 73.86 | 75.73 | 77.00 | 74.91 | 84.17 | 100.70 |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 43.11 | 46.92 | 49.64 | 53.87 | 54.43 | 51.54 | 57.23 | 67.92 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 40.51 | 46.46 | 51.03 | 53.87 | 55.13 | 53.64 | 61.68 | 72.47 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

វិស័យសេវាកម្ម បន្តរួមចំណែកយ៉ាងសំខាន់ក្នុងដំណើររើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា។ នៅត្រីមាសទី១ ឆ្នាំ២០១១ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ខាងសេវាកម្ម អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១៣៤% ធៀបនឹងឆ្នាំមុន ដល់ ២០៩,៥លានដុល្លារ។ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ខាងសណ្ឋាគារ និងទេសចរណ៍ កើន ២៧៥៥% ដល់ ១០៧,៩លានដុល្លារ។ ភ្ញៀវទេសចរបរទេសមកដល់កម្ពុជា កើនឡើងទាំងតាមផ្លូវអាកាស (១៥%) ផ្លូវគោក និងផ្លូវទឹក (១២%)។ វិនិយោគខាងវិស័យកសិកម្ម ធ្លាក់ចុះ ៩៨% មកត្រឹម ៤,១លានដុល្លារ ខណៈដែលវិនិយោគខាងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៧៣% មកត្រឹម ៦៧,១លានដុល្លារ។ ទោះយ៉ាងនេះក្តី វិនិយោគក្នុងវិស័យកាត់ដេរបង្ហាញសញ្ញាងើបឡើងវិញ ដោយកើន ១៣៤% ដល់ ៥៧,១លានដុល្លារ។ វិស័យសាងសង់ កំពុងងើបឡើងវិញដែរ ដោយតម្លៃនៃការសាងសង់ផ្ទះល្វែង កើនឡើង ៤៥% ដល់ ១៦,១លានដុល្លារ ប៉ុន្តែតម្លៃនៃការសាងសង់ផ្ទះវីឡា និងផ្ទះធម្មតា ធ្លាក់ចុះ ២០% មកត្រឹម ៤,១លានដុល្លារ ស្របពេលដែលសំណង់ផ្សេងៗទៀតធ្លាក់ចុះ ៣៣% មកត្រឹម ៤៣,៨លានដុល្លារ។

នៅត្រីមាសទី១ ឆ្នាំ២០១១ ការនាំចេញសរុប កើនឡើង ៤១% ធៀបនឹងត្រីមាសទី១ឆ្នាំមុន ដល់១០១៧,៧លានដុល្លារ ដោយក្នុងនេះ ការនាំចេញសំលៀកបំពាក់ មាន ៨៧%។ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក នៅតែជាទិសដៅនាំចេញដ៏ចម្បងដដែល ប៉ុន្តែកំណើនការនាំចេញទៅសហរដ្ឋអាមេរិក (២២%) វាទាបជាងទៅសហភាពអឺរ៉ុប (៦៩%) អាស៊ាន (៧៣%) ជប៉ុន (៧៣%) និងកន្លែងដទៃទៀតក្នុងពិភពលោក (៧០%)។ ការនាំចេញផលិតផលកសិកម្ម កើនឡើង ២៤៩% ដល់ ៧៤លានដុល្លារ ស្របពេលដែលការនាំចេញត្រី ធ្លាក់ចុះ ២៥% មកត្រឹម ០,៦លានដុល្លារ។

នៅត្រីមាសទី១នេះដែរ ការនាំចូលសរុបកើនឡើង ៤៤% ដល់ ៧២៨,៦លានដុល្លារ ក្នុងនេះប្រេងសាំង មានចំណែកប្រមាណ ៨,៥% និងម៉ាស៊ូត ១៣% ហើយការនាំចូលសាំង កើន ១១៥% និងម៉ាស៊ូត កើន ៨៦%។ ការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ១៤% មកត្រឹម ១១,៨លានដុល្លារ ដោយសារកំណើនដ៏យឺតក្នុងវិស័យអចលនវត្ថុ។ អតិរេកជញ្ជីងពាណិជ្ជកម្មកម្ពុជា សម្រាប់ត្រីមាសនេះ កើន ៥៣% ធៀបនឹងឆ្នាំមុន ដល់ ២៨៩លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល អនុវត្តបានល្អក្នុងការបង្កើតប្រាក់ចំណូលកាលពីឆ្នាំទៅ បើធៀបនឹង ១ឆ្នាំមុននោះទៀត។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ប្រាក់ចំណូលសរុបពីមួយឆ្នាំទៅមួយឆ្នាំ កើន ២៤% ដល់ ១៦៧៥ពាន់លានរៀល ក្នុងនេះចំណូលចរន្តមានប្រមាណ ៩៤% ចំណូលពន្ធ មាន ៧៣% និងចំណូលមូលធន ៦,២%។ ប៉ុន្តែកំណើនជាភាគរយនៃចំណូលពន្ធ (០,៥%) នៅមានកម្រិតទាបបើធៀបនឹងចំណូលចរន្ត (១៧%) និងចំណូលមូលធន (១១១៤%)។ ក្នុងរយៈពេលដដែល ចំណាយសរុប កើន ៣,៦% ដល់ ១៩៤៥,៤ពាន់លានរៀល ក្នុងនេះចំណាយមូលធនកើន ៦,៤% ដល់ ៦៧៥,៦ពាន់លាលរៀល ប៉ុន្តែចំណាយចរន្ត ធ្លាក់ចុះ ៤,៦% មកត្រឹម ១២៦៩,៨ពាន់លានរៀល។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ប្រាក់បៀវត្សរ៍ មានចំណែក ៤៥% ក្នុងចំណាយចរន្ត ហើយចំណែកនៃឧបត្ថម្ភធន និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ចមាន ១៨%។ គួបផ្សំមក ចំណូល និងចំណាយសរុប នៅត្រីមាសទី៤ បង្កឲ្យមានឱនភាពថវិកា ២០៧,៣ពាន់លានរៀល ធៀបនឹងអតិរេក ៩០,២ពាន់លានរៀលកាលពីមួយឆ្នាំមុន។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី១ ឆ្នាំ២០១១ ថ្លៃទំនិញទាំងអស់ កើនឡើង ៣,៦% ធៀបនឹងកាលពីមួយឆ្នាំមុន ក្នុងនេះ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៣,៩% ហើយថ្លៃដឹកជញ្ជូន កើន ៥,០%។ ក្នុងត្រីមាសដដែល ប្រាក់រៀលឡើងថ្លៃ ៣,៣% ដល់ ៤០៤១,៩រៀល/ដុល្លារសហរដ្ឋអាមេរិក និងឡើងថ្លៃ ១១% ធៀបនឹងប្រាក់ដុងវៀតណាម។ មាសឡើងថ្លៃ ២៦% ដល់ ១៦៨,៣ដុល្លារក្នុងមួយជី ហើយប្រេងម៉ាស៊ូត ឡើងថ្លៃ ២៣% ដល់ ៤៤២៧,២រៀលក្នុងមួយលីត្រ និងប្រេងសាំងឡើងថ្លៃ ១៤% ដល់ ៤៧៥០,១រៀលក្នុងមួយលីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅឆ្នាំ២០១០ សាច់ប្រាក់ងាយស្រួលសរុប (M2) កើនឡើង ១៨% ដល់ ១៨.៤៦៦ពាន់លានរៀល ធៀបនឹង ១៤.៣៧២ពាន់លានរៀល កាលពីមួយឆ្នាំមុន។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ទ្រព្យសកម្មបរទេសសុទ្ធ ធ្លាក់ចុះ ១,២% មកត្រឹម ១៦,៦៩៨ពាន់លានរៀល ស្របពេលដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើនឡើង ៤០% ដល់ ២៧៧៩ពាន់លានរៀល។ ក្នុងរយៈពេលដដែល ប្រាក់រៀលចរាចរ កើនឡើង ៥,២% ដល់ ៣២២១ពាន់លានរៀល ហើយរូបិយវត្ថុផ្សេងៗ កើនឡើង ២,៧% ដល់ ១៦.២៥៦ពាន់លានរៀល។

## ស្ថានភាពក្រីក្រ

អង្កេតពលករងាយរងគ្រោះរបស់វិទ្យាស្ថាន CDRI ក្នុងខែឧសភា ២០១១ បង្ហាញថា ក្នុងចំណោមក្រុមពលករមិនមែនខាងកាត់ដេរទាំង ៩ក្រុម មានតែ ២ក្រុមប៉ុណ្ណោះ ដែលបានថយចុះប្រាក់ចំណូល។ អ្នកធាក់ស៊ីក្លូ រងគ្រោះខ្លាំងជាងគេ ដោយសារប្រាក់ចំណូលពិតរបស់ខ្លួន ធ្លាក់ចុះ ១៣% បន្ទាប់មក គឺអ្នកស៊ីឈ្នួលធ្វើស្រែ (ធ្លាក់ចុះ ៤,០%)។ ចំណែកឯកម្មករសំណង់មានជំនាញ អ្នកលក់បន្លែ កម្មករលីសែង អ្នករត់ម៉ូតូឌុប អ្នកបម្រើតុភោជនីយដ្ឋាន អ្នករើសអេតចាយ និងកម្មករសំណង់គ្មានជំនាញ បានកើនប្រាក់ចំណូលពិត។

ដូចមានចុះក្នុងតារាង ៨ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនឡើង ១៨% ធៀបនឹងខែឧសភាឆ្នាំមុន ដល់ ៨៦៦១រៀលក្នុងមួយថ្ងៃ ចំណែកឯចំណាយប្រចាំថ្ងៃជាមធ្យម

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ កញ្ញា អ៊ួន វិមល និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅ វិទ្យាស្ថាន CDRI។

របស់ពួកគាត់ ធ្លាក់ចុះ ៥,០% មកត្រឹម ៤០១៥រៀល/ថ្ងៃ។ ក្នុងចំណោមអ្នករើសអេតចាយឆ្លើយសម្ភាសន៍មាន ៨៣% និយាយថា ប្រភពរបស់អេតចាយបានធ្លាក់ចុះ បើធៀបនឹងក្នុងបីខែមុន។ ទោះជាយ៉ាងនេះក្ដី មាន ៦០% រាយការណ៍ថា របស់អេតចាយបានឡើងថ្លៃ។ អ្នករើសអេតចាយ ៩០% បានធ្វើចំណាកស្រុកពីខេត្តនានា ពិសេសខេត្តព្រៃវែង តាកែវ កណ្ដាល ស្វាយរៀង និងសៀមរាប។

ប្រាក់ចំណូលរបស់អ្នកបម្រើតុភោជនីយដ្ឋាន បានកើនឡើង ១៣% ធៀបនឹងខែឧសភា ២០១០ ដល់ ៦០៦៦រៀលក្នុងមួយថ្ងៃ។ រយៈពេលធ្វើការជាមធ្យមប្រចាំថ្ងៃរបស់ពួកគេគឺ ១២ម៉ោង ដែលវែងជាងគេក្នុងចំណោមពលកររងាយរងគ្រោះទាំង ១០ក្រុម។ អ្នកឆ្លើយសម្ភាសន៍ទាំង ៤០នាក់ ក្នុងក្រុមនេះ ប្រាប់ថា ពួកគេមកធ្វើការតែម្នាក់ឯងនៅភ្នំពេញ។ អ្នកបម្រើតុភោជនីយដ្ឋានឆ្លើយសម្ភាសន៍ ៤៥% បានចូលរៀននៅមធ្យមសិក្សា។

ប្រាក់ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ៦,៧% ដល់ ៨៥៩៩រៀលក្នុងមួយថ្ងៃ នៅខែឧសភា ២០១១។ អ្នកលក់បន្លែតូចតាចឆ្លើយសម្ភាសន៍ទាំង ៤០នាក់ និយាយថា ប្រាក់ចំណូលរបស់ខ្លួន បានត្រឹមតែមួយគ្រប់ សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារប៉ុណ្ណោះ។ មូលធនជាមធ្យមរបស់ពួកគាត់ គឺ ៥០.០០០រៀល ដែលទាបជាងខែកុម្ភៈ ១៣% ហើយអ្នកលក់បន្លែ ៧០% និយាយថា ចំនួននេះមិនគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្មទេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើនឡើង ៥,៦% ធៀបនឹងខែឧសភា ២០១០ ដល់ ៩៨៦១រៀលក្នុងមួយថ្ងៃ ហើយចំណាយរបស់ពួកគាត់ ធ្លាក់ចុះ ៤,៩% ពី ៥៦៨៩រៀលក្នុងមួយថ្ងៃ មកត្រឹម ៥៤១២រៀលក្នុងមួយថ្ងៃ។ ៧០% នៃអ្នកឆ្លើយសម្ភាសន៍និយាយថា ពួកគេជួលផ្ទះនៅរួមគ្នា ដោយផ្ទះមួយនៅ ៧នាក់ជាមធ្យម ហើយ ៣០% ទៀត រស់នៅតាមចិញ្ចើមថ្នល់ ឬនៅតាមវត្ត។ អ្នកឆ្លើយសម្ភាសន៍ ៧០% និយាយថា ស្ថានភាពគ្រួសារខ្លួន ល្អប្រសើរឡើង ចាប់ពីបានមកប្រកបរបរនេះ ហើយ ២៣% និយាយថា នៅដដែល និង ៧% និយាយថា កាន់តែលំបាកឡើង។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើនឡើង ៦,១% ធៀបនឹងខែឧសភា ២០១០ ដល់ ៧៩៥០រៀលក្នុងមួយថ្ងៃ រីឯចំណាយប្រចាំថ្ងៃ ធ្លាក់ចុះ ៥,៧% ពី ៤៨៥៣រៀលក្នុងមួយថ្ងៃ មកត្រឹម ៤៥៧៧រៀលក្នុងមួយថ្ងៃ។ ពួកគេបានមកធ្វើការក្នុងរោងចក្រអស់រយៈពេលប្រមាណ ៣ឆ្នាំហើយ ហើយមាន ៤៤% បានផ្លាស់ប្ដូររោងចក្រ។ កម្មករឆ្លើយសម្ភាសន៍ ៤០% និយាយថា ពួកគេប្ដូររោងចក្រដោយសារ មានជម្ងឺ ២% ដោយសារមានបញ្ហាជាមួយអ្នកត្រួតការ ៣៤% ដោយសាររោងចក្របិទទ្វារ និង ២៥% ដោយសារបញ្ហាផ្សេងៗទៀត។ បើសិនជារោងចក្រដែលខ្លួនកំពុងបម្រើការត្រូវបិទទ្វារ ៥៣% នៃអ្នកឆ្លើយសម្ភាសន៍គិតថានឹងស្វែងរកការងារផ្សេងទៀតធ្វើនៅរាជធានីភ្នំពេញ ឯ ៤២% នឹងត្រឡប់ទៅស្រុកវិញ ហើយ ៥% មិនទាន់ដឹងទេ។

នៅខែកុម្ភៈ ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែធ្លាក់ចុះស្របពេលដែល ៩ក្រុមទៀត កើនចំណូលឡើង។ ការធ្លាក់ចុះនេះបន្តរហូតដល់ខែឧសភា ដែលនៅពេលនោះប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពួកគេ ធ្លាក់ចុះ ៤,៤% មកត្រឹម ៥៩៨៤រៀលក្នុងមួយថ្ងៃ។ ពលករឆ្លើយសម្ភាសន៍ ៥៧% មានដីដាំដុះតិចជាងមួយហិកតា ៣៨% គ្មានដីទេ ៣% មានដី ១ហិកតា និង ៣% ទៀត មានដីលើសពីមួយហិកតា។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ មិនដែលបានលើសពី ១០,០០០រៀលក្នុងមួយថ្ងៃទេ តាំងពីឆ្នាំ២០០៨ មក ប៉ុន្តែបានឡើងដល់ ១០.៦៣៣រៀលក្នុងមួយថ្ងៃ នៅខែកុម្ភៈ ២០១១។ បន្ទាប់ពីមានកំណើនខ្លាំង ប្រាក់ចំណូលពិតជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ បានធ្លាក់ចុះ ២២% នៅខែឧសភា បើប្រៀបធៀបនឹងរយៈពេល ៣ខែមុន និងធ្លាក់ចុះ ១៣% ធៀបនឹងខែឧសភាឆ្នាំមុន។ មានអ្នកធាក់ស៊ីក្លូឆ្លើយសម្ភាសន៍តែ ២០% ប៉ុណ្ណោះ ដែលមានស៊ីក្លូផ្ទាល់ខ្លួន ឯក្រៅពីនោះត្រូវជួលស៊ីក្លូពីគេ។ សមាមាត្រអ្នកធាក់ស៊ីក្លូ ដែលរស់នៅតាមចិញ្ចើមថ្នល់ នឹងរស់នៅតាមវត្ត កើនឡើងពី ៦៣% នៅខែកុម្ភៈ ទៅដល់ ៦៨% នៅខែឧសភា ឆ្នាំ២០១១។ រយៈពេលមធ្យមដែលពួកគេប្រកបរបរនេះគឺ ៩ឆ្នាំ។

---

*តពីទំព័រ ១៤* "***ការពង្រឹងផលចំណេញ*****....."**

សម្ពាធពីសង្គម និងក្រុមគ្រួសារ ឲ្យចូលរៀនក្នុង HEIs និងចូលបម្រើការងារការិយាល័យ ដែលគេគិតថាបានប្រាក់ខែខ្ពស់ជាង។ គំនិតនេះខុសពីការពិតខ្លាំងណាស់ ដែលនាំឲ្យអ្នកមានសញ្ញាប័ត្រឧត្ដមសិក្សាភាគច្រើន ទទួលបានតំណែងទាបជាងសមត្ថភាពរបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហា គេត្រូវប្ដូរឈ្មោះថ្មីឲ្យការអប់រំ និងការបណ្ដុះបណ្ដាលបច្ចេកទេស វិជ្ជាជីវៈ (TVET) នេះ ដើម្បីឆ្លុះបញ្ចាំងពីការពិត ដែលកម្មវិធីនេះផ្ដល់ឲ្យបុគ្គលម្នាក់ៗនូវជំនាញ ដែលបង្កើនលទ្ធភាពរកបានការងាររបស់ពួកគេ។ ការបញ្ជ្រាប និងសម្របសម្រួលកម្មវិធី TVET ព្រមទាំងប្រព័ន្ធទទួលស្គាល់គុណភាពសមស្រប ក៏រួមចំណែកជួយកែប្រែគំនិតនេះបានច្រើនដែរ។

បច្ចុប្បន្នមានតម្រូវការកាន់តែច្រើនឡើង ដើម្បីបង្កើនទំនាក់ទំនងរវាងវិស័យឯកជន អ្នករៀបចំគោលនយោបាយ និងកម្លាំងពលកម្ម។ ចំណុចនេះសំខាន់ណាស់ ជាពិសេសនៅពេលកម្ពុជាកំពុងប្រឹងប្រែងធ្វើពិពិធកម្ម និងឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម ហើយតម្រូវការរបស់និយោជកក៏អាចប្រែប្រួលយ៉ាងឆាប់រហ័ស។ គោលនយោបាយ ត្រូវតែយកចិត្តទុកដាក់ និងឆ្លើយតបយ៉ាងសកម្មនឹងការប្រែប្រួលទាំងនេះ ដើម្បីឲ្យកម្មវិធីបណ្ដុះបណ្ដាលផ្សេងៗ អាចសម្របខ្លួនបានលឿនតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្ដែង ហើយកម្លាំងពលកម្ម ក៏អាចទាញយកប្រយោជន៍បានលឿនពីឱកាសល្អនានា ដែលទើបផុសឡើង។ ឧទាហរណ៍ថ្មីស្រឡាងមួយ គឺតម្រូវការបណ្ដុះបណ្ដាលជាបន្ទាន់ ដើម្បីទាញយកប្រយោជន៍ឲ្យបានច្រើនជាអតិបរមា ពីឱកាសល្អនានាដែលកំពុងផុសឡើងក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZs)។ ដើម្បីកំណត់បានពីតម្រូវការទីផ្សារពលកម្ម ដែលកំពុងផុសឡើងនេះ ត្រូវមានការសិក្សាស្រាវជ្រាវជាក់ស្ដែងស៊ីជម្រៅដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្ដល់ព័ត៌មានអំពីទីផ្សារពលកម្មឲ្យបានទាន់ពេលដល់អ្នករៀបចំគោលនយោបាយ។

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92 | 175.3 | 176.1 | 94.4 | 165.7 | 41.4 | 278.0 | 36.7 | 4.1 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 60.6 | 685.5 | 247.7 | 54.5 | 44.3 | 87.7 | 67.1 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *21.9* | *14.2* | *13.1* | *21.3* | *29.3* | *50.0* | *57.1* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 495.6 | 150.2 | 3475.8 | 89.5 | 121.6 | 0 | 1096.2 | 209.5 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *150.2* | *0.0* | *3.78* | *14.0* | *0* | *1087.4* | *107.9* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 386.3 | 4255.7 | 502.9 | 217.5 | 322.3 | 1220.6 | 280.72 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -41.2 | 882.0 | 1001.7 | -91.2 | -56.8 | 48.2 | 278.8 | -77.0 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -91.5 | 169.3 | -59.8 | 452.0 | -16.6 | -71.3 | -44.2 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 15.6 | 9.8 | 5.1 | 7.5 | 14.1 | 9.5 | 4.1 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 7.4 | 28.0 | 11.1 | 127.2 | 25.3 | 20.3 | 16.1 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 68.4 | 29.0 | 35.2 | 67.4 | 38.9 | 76.2 | 23.6 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 181.1 | 91.4 | 66.8 | 51.4 | 202.1 | 78.4 | 106.0 | 43.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -48.5 | 46.6 | -26.9 | -23.1 | 293.2 | -61.2 | 35.3 | -58.7 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -81.2 | -81.0 | -71.6 | 224.4 | -14.2 | 58.7 | -14.8 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 247.2 | 308.1 | 371.5 | 260.9 | 288.3 | 383.7 | 427.4 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 240.2 | 279.5 | 312.2 | 276.6 | 293.8 | 321.4 | 351.0 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 487.4 | 587.6 | 683.7 | 537.5 | 582.0 | 705.1 | 778.4 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 7.7 | 5.0 | 20.6 | 16.4 | -21.4 | 8.3 | 21.2 | 10.4 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 9.4 | 1.7 | 9.9 | 15.8 | 19.4 | 20.0 | 13.9 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2352.8 | 2810.9 | 3050.3 | 3097.8 | 697.4 | 709.9 | 736.5 | 693.8 | 820.7 | 1045.3 | 1070.3 | 1017.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2253.3 | 2698.8 | 2938.9 | 2986.2 | 667.1 | 601.4 | 660.7 | 625.5 | 716.8 | 938.3 | 942.7 | 880.5 |
| *- ទៅសហរដ្ឋអាមេរិក* | 1546.1 | 1847.2 | 1956.5 | 1908.3 | 387.6 | 372.9 | 388.5 | 380.5 | 416.7 | 531.9 | 524.7 | 464.5 |
| *- ទៅសហភាពអឺរ៉ុប* | 503.1 | 601.0 | 654.2 | 689.0 | 183.1 | 128.0 | 165.5 | 137.2 | 184.8 | 239.4 | 248.0 | 232.0 |
| *- ទៅអាស៊ាន* | 2.3 | 2.6 | 3.2 | 10.8 | 1.0 | 1.3 | 2.9 | 2.2 | 1.9 | 2.9 | 3.0 | 3.8 |
| *- ទៅជប៉ុន* | 23.5 | 29.4 | 28.5 | 25.2 | 5.2 | 9.5 | 14.3 | 19.8 | 14.9 | 25.5 | 26.2 | 34.3 |
| *- ទៅប្រទេសផ្សេងៗ* | 178.3 | 218.7 | 296.4 | 352.9 | 90.2 | 89.6 | 89.6 | 85.7 | 98.6 | 138.6 | 140.7 | 145.9 |
| កសិកម្ម | 61.3 | 59.7 | 55.6 | 44.5 | 8.0 | 15.1 | 25.9 | 21.2 | 27.2 | 44.8 | 71.7 | 74.0 |
| *- កៅស៊ូ* | 36.8 | 41.5 | 41.0 | 35.8 | 5.1 | 11.8 | 16.5 | 11.9 | 13.8 | 25.3 | 38.1 | 49.9 |
| *- ឈើ* | 10.3 | 8.6 | 8.7 | 3.4 | 0.7 | 0.6 | 1.8 | 2.7 | 4.5 | 8.8 | 18.1 | 6.2 |
| *- ត្រី* | 10.1 | 5.9 | 3.2 | 2.3 | 0.7 | 0.8 | 1.2 | 0.8 | 0.7 | 0.5 | 0.8 | 0.6 |
| *- ផ្សេងៗ* | 4.2 | 3.7 | 2.7 | 3.1 | 1.5 | 1.9 | 6.3 | 5.7 | 8.2 | 10.2 | 14.7 | 17.3 |
| ផ្សេងៗ | 38.3 | 52.3 | 55.8 | 67.1 | 22.3 | 93.4 | 50.0 | 47.1 | 76.7 | 62.2 | 55.9 | 63.2 |
| ការនាំចូលសរុប | 2513.0 | 512.2 | 554.8 | 1010.9 | 585.3 | 484.4 | 532.8 | 505.6 | 563.2 | 731.3 | 677.1 | 728.7 |
| ក្នុងនេះ៖ សាំង | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 19.3 | 19.4 | 28.8 | 22.4 | 27.6 | 30.5 | 62.0 |
| ម៉ាស៊ូត | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 46.0 | 43.1 | 49.8 | 55.4 | 48.0 | 50.5 | 92.5 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 15.7 | 13.3 | 13.7 | 13.2 | 16.7 | 13.8 | 11.8 |
| ផ្សេងៗ | 2245.0 | 303.9 | 304.3 | 749.5 | 520.5 | 403.4 | 457.0 | 413.3 | 472.2 | 638.9 | 582.3 | 562.4 |
| ជញ្ជីងពាណិជ្ជកម្ម | -160.2 | 2298.7 | 2495.5 | 2086.9 | 112.1 | 225.5 | 203.7 | 188.2 | 257.5 | 314.0 | 393.2 | 289.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | -9.9 | 23.0 | -8.1 | -5.3 | 14.6 | 30.9 | 0.5 | -6.6 |
| ការនាំចេញសរុប | - | - | - | - | 1.8 | 23.4 | -8.4 | -5.8 | 18.3 | 27.4 | 2.4 | -4.9 |
| ការនាំចូលសរុប | - | - | - | - | 2.8 | -20.3 | 10.0 | -5.1 | 11.4 | 29.8 | -7.4 | 7.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 11.2 | 19.8 | 8.9 | 1.6 | -19.7 | -16.5 | -1.0 | 4.0 | 22.6 | 30.5 | 42.7 | 40.8 |
| ការនាំចេញសរុប | 11.6 | 19.5 | 8.5 | 1.6 | -7.6 | -10.2 | 5.6 | -2.3 | 26.0 | 30.0 | 45.3 | 46.7 |
| ការនាំចូលសរុប | 189.6 | -79.6 | 8.3 | 82.2 | 0.2 | -8.4 | 13.7 | -14.5 | -7.4 | 51.0 | 27.1 | 44.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site).*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១០ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 |

*Source: MEF web site.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -2.7 | 1.8 | 7.8 | 3.6 | 1.9 | 4.1 | 3.9 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -13.8 | 2.4 | 12.9 | 8.7 | 3.2 | 3.1 | 5.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4164.4 | 4157.3 | 4180.1 | 4209.0 | 4236.7 | 4122.6 | 4041.9 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 122.9 | 126.0 | 127.0 | 129.9 | 138.3 | 137.3 | 132.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.5 | 23.0 | 22.3 | 22.1 | 21.4 | 21.1 | 19.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 123.2 | 133.8 | 133.9 | 142.9 | 147.8 | 165.7 | 168.3 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3867.0 | 3381.9 | 3599.5 | 3835.1 | 3936.6 | 4066.1 | 4427.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3371.1 | 3940.2 | 4163.0 | 4358.7 | 4415.5 | 4535.2 | 4750.1 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6 | 12,610.9 | 16,903.0 | 16,697.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2,120.4 | -2126.6 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 | 12,479.8 | 13,331.2 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 | 18,887.8 | 19,476.8 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 | 15,826.1 | 16255.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | 2010 | 2011 | |
| | | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 7469 | 8075 | 12,628 | 8091 | 9570 | 8404 | 8759 | 10,633 | 8292 | 21.7 | 13.0 | -13.4 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 9340 | 10,525 | 9965 | 11,184 | 9861 | 7.8 | 12.4 | 5.6 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 8062 | 8291 | 8821 | 9149 | 8599 | 19.4 | 16.9 | 6.7 |
| អ្នករើសអេតចាយ | 4416 | 5422 | 4652 | 5857 | 7407 | 6461 | 6628 | 6931 | 8661 | 46.1 | 11.1 | 16.9 |
| អ្នកបំរើភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 5380 | 6427 | 5448 | 6154 | 6066 | 1.3 | 19.9 | 12.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 6260 | 6186 | 4912 | 4806 | 5984 | 1.6 | -10.3 | -4.4 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 7491 | 8470 | 7944 | 8312 | 7950 | 6.2 | 10.0 | 6.1 |
| អ្នករត់ម៉ូតូឌុប | 8201 | 10,634 | 15,691 | 10,685 | 10,274 | 10,558 | 10,278 | 11,444 | 10,630 | 9.7 | 1.3 | 3.5 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 9013 | 8744 | 9636 | 11,291 | 9415 | 22.6 | 46.7 | 4.5 |
| កម្មករសំណង់មានជំនាញ | 10,316 | 11,154 | 12,710 | 12,487 | 11,928 | 11,738 | 12,122 | 12,487 | 12,368 | -3.6 | 4.7 | 3.7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*